# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

**ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៥/០៧**

**ស្តីអំពីការបង្កើតខេត្ត ឧត្តរមានជ័យ**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស**

**ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់ឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់ឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ អំពីសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ក្រាស់បង្គាប់**

**មាត្រា ១ :** ត្រូវបានបង្កើតខេត្តឧត្តរ មានជ័យ ។ អាជ្ញាធរដែលមានសមត្ថកិច្ចគ្រប់គ្រងខេត្តនេះ ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** ខេត្តឧត្តរមានជ័យរួមមាន ៤ ស្រុក គឺ : ស្រុកសំរោង ស្រុកចុងកាល់ ស្រុកអន្លង់វែង និង ស្រុកបន្ទាយអំពិល ។

**មាត្រា ៣ :** យកស្រុកសំរោង ស្រុកចុងកាល់ និង ស្រុកអន្លង់វែង ត្រូវបានកាត់យកពីភូមិសាស្ត្រ ខេត្តសៀមរាប-ឧត្តរមានជ័យ ។

ត្រូវបានផ្តាច់យកស្រុកបន្ទាយអំពិល ពីភូមិសាស្ត្រ ខេត្តបន្ទាយមានជ័យ ។

**មាត្រា ៤ :** ស្រុកសំរោងមាន ៤ ឃុំគឺ : ឃុំសំរោង ឃុំកូនក្រៀល ឃុំបុស្ស និង ឃុំបន្សាយរាក់ ។

- ស្រុកចុងកាល់មាន ៤ ឃុំគឺ : ឃុំចុងកាល់ ឃុំក្រសាំង ឃុំពង្រ និង ឃុំជើងទៀន ។
- ស្រុកអន្លង់វែងមាន ៥ ឃុំគឺ : ឃុំអន្លង់វែង ឃុំឫស្សី ឃុំត្រពាំងតាវ ឃុំថ្លាវ និង ឃុំរំចេក ។
- ស្រុកបន្ទាយអំពិលមាន ៤ ឃុំគឺ : ឃុំអំពិល ឃុំគោកខ្ពស់ ឃុំគោកមន និង ឃុំបេង ។

**មាត្រា ៥ :** ទីតាំងសាលាខេត្តឧត្តរមានជ័យ ស្ថិតនៅឃុំសំរោង ស្រុកសំរោង ។

**មាត្រា ៦ :** ខេត្តសៀមរាប-ឧត្តរមានជ័យបច្ចុប្បន្ន ត្រូវប្ដូរឈ្មោះមកជាខេត្តសៀមរាបវិញ ។

**មាត្រា ៧ :** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍

**មាត្រា ៨ :** នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៩ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីពេលឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ និង ជំរាប

សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា និង ត្រា

**ស ខេង**

ហត្ថលេខា និង ត្រា

**យូ ហុកគ្រី**

ទទួលព្រះរាជបញ្ជាព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១

**នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២

**ហ៊ុន សែន**